ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថានឯកអគ្គរាជទូតកម្ពុជា
ប្រចាំប្រទេសបារាំង

លេខ ២៥២ -២០២១/ARC/AG

# សេចក្តីជូនដំណឹង

ស្ថានឯកអគ្គរាជទូតកម្ពុជានៅទីក្រុងប៉ារីស សូមជម្រាបជូនប្រជាពលរដ្ឋ សិស្ស និងនិស្សិតខ្មែរ **ទាំងអស់** អំពីបច្ចុប្បន្នភាពនៃការបន្ធូរបន្ថយវិធានការរឹតត្បិតការធ្វើដំណើរចេញ-ចូលប្រទេសបារាំង របស់រដ្ឋាភិបាលបារាំង ដោយផ្អែកលើស្ថានភាពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងការចាក់វ៉ាក់សាំងរបស់អ្នកធ្វើដំណើរ នៃប្រទេសគោលដៅ និងប្រទេសចេញដំណើរ ដូចខាងក្រោម៖

ដោយបច្ចុប្បន្ន ប្រទេសកម្ពុជាត្រូវបានចាត់ចូលជាក្រុមប្រទេសពណ៌ទឹកក្រូច (១) លក្ខខណ្ឌខាងក្រោម នឹងត្រូវអនុវត្ត៖

1. ចំពោះអ្នកដំណើរដែលទទួលបានវ៉ាក់សាំងពេញលេញ (២)

➢ **ការធ្វើដំណើរចាកចេញពីប្រទេសបារាំង** ទៅកម្ពុជា៖
- ពុំតម្រូវឱ្យមានលិខិតបញ្ជាក់ពីមូលហេតុចាំបាច់បំផុតទេ
- ត្រូវធ្វើតេស្តអវិជ្ជមានកូវីដ-១៩ (PCR) ក្រោម ៧២ ម៉ោង (ឬក្រោម ៤៨ ម៉ោង សម្រាប់ការឆ្លងកាត់ប្រទេសមួយចំនួន) មុនធ្វើដំណើរ និងធ្វើតេស្តនេះបន្ថែមទៀត ពេលទៅដល់កម្ពុជា។
- និងធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ ដដែល។

➢ ការធ្វើដំណើរពីប្រទេសកម្ពុជា **ចូលមកប្រទេសបារាំង**៖
- ពុំតម្រូវឱ្យមានលិខិតបញ្ជាក់ពីមូលហេតុចាំបាច់បំផុតទេ
- តម្រូវឱ្យធ្វើតេស្តអវិជ្ជមានកូវីដ-១៩ (PCR) ក្រោម៧២ម៉ោង (ឬក្រោម ៤៨ ម៉ោង សម្រាប់ការឆ្លងកាត់ប្រទេសមួយចំនួន) ឬការធ្វើតេស្តលឿន (Antigénique) ក្រោម៤៨ម៉ោង មុនពេលឡើងយន្តហោះ។

2. ចំពោះអ្នកដំណើរដែលមិនទាន់បានចាក់វ៉ាក់សាំងពេញលេញ
- ត្រូវបង្ហាញហេតុផលចាំបាច់បំផុតដើម្បីធ្វើដំណើរទៅប្រទេសបារាំង និងលទ្ធផលតេស្តអវិជ្ជមានកូវីដ-១៩ (PCR) ក្រោម៧២ម៉ោង (ឬក្រោម ៤៨ ម៉ោង សម្រាប់ការឆ្លងកាត់ប្រទេសមួយចំនួន) ឬការធ្វើតេស្តលឿន ក្រោម៤៨ម៉ោង។
- ការធ្វើតេស្តអាចធ្វើឡើងផងដែរនៅពេលទៅដល់ប្រទេសបារាំង
- និងត្រូវដាក់ខ្លួននៅដាច់ដោយឡែករយៈពេល ៧ថ្ងៃ នៅពេលមកដល់ប្រទេសបារាំង។

ស្ថានឯកអគ្គរាជទូតកម្ពុជានៅទីក្រុងប៉ារីសសូមជម្រាបជូនផងដែរថា សម្រាប់ពលរដ្ឋខ្មែរដែលបានចាក់វ៉ាក់សាំងប្រឆាំងជំងឺកូវីដ-១៩ (២) ពេញលេញពីប្រទេសកម្ពុជារួចហើយ អាចស្នើសុំប្តូរជាប័ណ្ណសុខភាព (Passe sanitaire) ដែលមានតម្លៃស្មើប័ណ្ណចាក់វ៉ាក់សាំងអឺរ៉ុប ដោយត្រូវបំពេញបែបបទតាមតំណភ្ជាប់ ដូចខាងក្រោម៖

–សម្រាប់ជនបរទេសទូទៅ សូមចូលទៅកាន់៖
https://www.demarches-simplifiees.fr/commencer/passe-sanitaire-etrangers

–សម្រាប់សិស្សនិស្សិតបរទេស សូមចូលទៅកាន់៖
https://www.demarches-simplifiees.fr/commencer/passe-sanitaire-etudiants

–សម្រាប់អ្នកការទូតមកបំពេញបេសសកកម្មផ្លូវការ សូមចូលទៅកាន់៖
https://www.demarches-simplifiees.fr/commencer/passe-sanitaire-diplomates

សូមរំលឹកថាការផ្តល់សេវាកម្មកុងស៊ុល គឺរយៈពេល៥ថ្ងៃ ក្នុង១សប្តាហ៍ ពីថ្ងៃចន្ទ ដល់ សុក្រ ពេលព្រឹក ពីម៉ោង ១០:០០នាទី ដល់ម៉ោង ១២:៣០នាទី និងពេលរសៀល ពីម៉ោង១៤:០០នាទី ដល់ម៉ោង ១៦:៣០នាទី។

ក្រៅពីពេលវេលាដូចបានកំណត់ខាងលើ សូមទាក់ទងមកស្ថានទូត តាមលេខទូរស័ព្ទ (+33) 1 45 03 47 20 និងអាសយដ្ឋានអ៊ីម៉ែល arc@ambcambodgeparis.info ។

ថ្ងៃពុធ ៩កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
ប៉ារីស ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០២១

(១)ប្រទេសនានាត្រូវបានចាត់ថ្នាក់ពណ៌«បៃតង» «ទឹកក្រូច» ឬ«ក្រហម

(២)

❖ វ៉ាក់សាំងដែលទទួលស្គាល់ដោយប្រទេសបារាំង រួមមាន៖ Pfizer, Moderna, AstraZeneca et Johnson et Johnson)។

❖ ការចាក់វ៉ាក់សាំងត្រូវបានចាត់ទុកថាពេញលេញនៅពេល៖

– ២សប្តាហ៍បន្ទាប់ពីការចាក់លើកទី២ សម្រាប់វ៉ាក់សាំង (Pfizer, Moderna, AstraZeneca)

– ៤សប្តាហ៍បន្ទាប់ពីការចាក់វ៉ាក់សាំងតែមួយដង សម្រាប់វ៉ាក់សាំង (Johnson & Johnson)

– ២សប្តាហ៍បន្ទាប់ពីការចាក់វ៉ាក់សាំងតែមួយដង (សម្រាប់បុគ្គលដែលធ្លាប់មានជំងឺកូវីដ-១៩)។